# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:..៩៤..អនក្រ.បក

## អនុក្រឹត្យ
## ស្ដីពី
## ការគ្រប់គ្រងអាងទន្លេ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងធនធានទឹកនិងឧតុនិយម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៦ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ៥៨ អនក្រ.បក ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៩៩ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងធនធានទឹកនិងឧតុនិយម
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៥

## សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះមានគោលបំណងគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍអាងទន្លេឱ្យមានប្រសិទ្ធភាពនិងនិរន្តរភាពដោយអនុលោមតាមច្បាប់ស្ដីពីការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២ .-**

អនុក្រឹត្យនេះមានគោលដៅកំណត់អំពីនីតិវិធីនៃការរៀបចំ និងការអនុវត្តផែនការនៃការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍអាងទន្លេ អាងទន្លេរង ទឹកលើដីជម្រាល ទឹកក្រោមដី និងល្អាងទឹកក្រោមដី។

**មាត្រា៣ .-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តលើគ្រប់អាងទន្លេក្នុងព្រះរាជាណាចក្រកម្ពុជា និងសហការជាមួយប្រទេសជិតខាងក្នុងការប្រើប្រាស់ទឹកលើគ្រប់វិស័យ។

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៩៨ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការគ្រប់គ្រងអាងទន្លេ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងធនធានទឹកនិងឧតុនិយម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៦ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ៥៨ អនក្រ.បក ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងធនធានទឹកនិងឧតុនិយម
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៥

## សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះមានគោលបំណងគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍអាងទន្លេឱ្យមានប្រសិទ្ធភាពនិងនិរន្តរភាពដោយអនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២ .-**

អនុក្រឹត្យនេះមានគោលដៅកំណត់អំពីនីតិវិធីនៃការរៀបចំ និងការអនុវត្តផែនការនៃការគ្រប់គ្រងការអភិរក្ស និងការអភិវឌ្ឍអាងទន្លេ អាងទន្លេរង ទឹកលើដីជម្រាល ទឹកក្រោមដី និងល្អាងទឹកក្រោមដី។

**មាត្រា៣ .-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តលើគ្រប់អាងទន្លេក្នុងព្រះរាជាណាចក្រកម្ពុជា និងសហការជាមួយប្រទេសជិតខាងក្នុងការប្រើប្រាស់ទឹកលើគ្រប់វិស័យ។

**មាត្រា៤ .-**

វាក្យសព្ទសំខាន់ៗដែលប្រើនៅក្នុងអនុក្រឹត្យនេះ រួមមានៈ

**អាងទន្លេ** សំដៅដល់តំបន់ភូមិសាស្ត្រដែលកំណត់ដោយព្រំប្រទល់ទីជម្រាលនៃប្រព័ន្ធទឹកហូរដោយរាប់បញ្ចូលទាំងទឹកលើដីនិងទឹកក្រោមដី។

**អាងទន្លេរង** សំដៅដល់ផ្នែកមួយនៃអាងទន្លេ។

**ទឹកក្រោមដី** សំដៅដល់ទឹកដែលហូរនៅក្រោមដីក្នុងចន្លោះថ្មតូចធំ និងភាគល្អិតនៃដីដែលផ្លាស់ទីពីកន្លែងមួយទៅកន្លែងមួយទៀត។

**ល្អាងទឹកក្រោមដី** សំដៅដល់ទឹកក្រោមដី ដែលស្ថិតនៅជាអចិន្ត្រៃយ៍ល្អាងធម្មជាតិក្រោមដី។

**សមុទ្រ** សំដៅដល់ប្រភពធនធានទឹកប្រៃ និងជាកន្លែងទទួលរំហូរទឹកមកពីទន្លេ ស្ទឹង ព្រែក ជ្រោះ អូរ ទឹកក្រោមដី និងពីតំបន់ផ្ទៃរងទឹកភ្លៀងនៅផ្នែកខាងលើ។

**ទន្លេ** សំដៅដល់ផ្លូវទឹកធម្មជាតិ ដែលទទួលប្រភពទឹកមកពីស្ទឹង ព្រែក ជ្រោះ អូរ ទឹកក្រោមដី និងពីតំបន់ផ្ទៃរងទឹកភ្លៀងនៅផ្នែកខាងលើ ហើយហូរចាក់ទៅសមុទ្រ។

**ស្ទឹង** សំដៅដល់ផ្លូវទឹកធម្មជាតិ ដែលទទួលប្រភពទឹកមកពីជ្រោះ អូរ ទឹកក្រោមដី និងពីតំបន់ផ្ទៃរងទឹកភ្លៀងនៅផ្នែកខាងលើ ហើយហូរចាក់ទៅបឹង ទន្លេ និងសមុទ្រ។

**ព្រែក** សំដៅដល់ផ្លូវទឹកធម្មជាតិឬសិប្បនិម្មិត ដែលនាំទឹកចេញឬចូលពីទន្លេឬស្ទឹង និងពីតំបន់ផ្ទៃរងទឹកភ្លៀងនៅផ្នែកខាងលើ។

**អូរ** សំដៅដល់ផ្លូវទឹកធម្មជាតិ ដែលទទួលប្រភពទឹកមកពីជ្រោះ និងពីតំបន់ផ្ទៃរងទឹកភ្លៀងនៅផ្នែកខាងលើ ហើយហូរចូលព្រែក ស្ទឹង ទន្លេ ឬបឹង។

**ជ្រោះ** សំដៅដល់ជ្រលងឬល្បាក់ទឹកធម្មជាតិ ដែលកើតឡើងដោយសារបាតុភូតធម្មជាតិនៃការហូរច្រោះដោយសារចរន្តទឹកពីតំបន់ភ្នំឬតំបន់ខ្ពង់រាប។

**បឹងបួ** សំដៅដល់ល្អាលទឹកធំល្វឹងល្វើយកើតពីទីជម្រាលឬជម្រៅធម្មជាតិ ដែលអាចមានទឹកឬគ្មានទឹកទៅតាមរដូវកាល និងមានប្រភពទឹកមកពីទន្លេ ស្ទឹង ព្រែក ឬពីតំបន់ផ្ទៃរងទឹកភ្លៀង។

**អាងទឹក** សំដៅដល់ទីតម្កល់ទឹកដែលកើតឡើងដោយធម្មជាតិឬសិប្បនិម្មិតសម្រាប់ប្រើទៅតាមតម្រូវការ។

**ឆ្នេរ សមុទ្រ ទន្លេ ស្ទឹង** សំដៅដល់ចំណែកដីឬខ្សាច់ដែលមានសណ្ឋានជម្រាល និងលិចទឹកម្តងម្កាល។

**ច្រាំងទន្លេ ស្ទឹង ព្រែក អូរ ប្រឡាយ បឹងបួ និងអាងទឹក** សំដៅដល់ចំណែកដីដែលធម្មតាលិចដោយទឹកនៅក្នុងទន្លេ ស្ទឹង ព្រែក អូរ ប្រឡាយ បឹងបួ និងអាងទឹក ដោយរាប់បញ្ចូលទាំងដី ថ្ម ឬអង្គធាតុដទៃទៀត ដែលជាប់នៅនឹង ច្រាំងនោះដោយមិនរាប់បញ្ចូលនូវដី ថ្ម ឬអង្គធាតុដទៃទៀត ដែលនៅឆ្ងាយពីច្រាំងនិងលិចទឹកម្តងម្កាលនោះទេ។

**មាត់ច្រាំង** សំដៅដល់ខ្សែបន្ទាត់ក្រិតកម្ពស់ទឹកខ្ពស់បំផុតនៅរដូវវស្សា លើកលែងតែករណីដែលមានទឹកជំនន់ខុសធម្មតា។

**មាត់ឆ្នេរ** សំដៅដល់ខ្សែបន្ទាត់ក្រិតកម្ពស់ទឹកជោរខ្ពស់បំផុតនៅសម[illegible]

| | |
|---|---|
| ពាមសមុទ្រ | សំដៅដល់តំបន់ចុងក្រោយនៃទន្លេ ស្ទឹង ព្រែក ដែលប្រសព្វជាមួយនឹងសមុទ្រ។ |
| រក្សាលំហូរ | សំដៅដល់របបលំហូរទឹកអប្បបរមាចាំបាច់ដែលត្រូវរក្សាឱ្យមាននៅក្នុងទន្លេ ស្ទឹង ព្រែក ដើម្បីធានាបាននូវនិរន្តរភាពនៃប្រព័ន្ធអេកូឡូស៊ី និងផលប្រយោជន៍ផ្សេងៗទៀត។ |
| តំបន់ហានិភ័យ | សំដៅដល់តំបន់ដែលងាយរងនូវការប៉ះពាល់ឬការខូចខាតធ្ងន់ធ្ងរដែលបណ្តាលមកពីកត្តាមនុស្សនិងធម្មជាតិ។ |
| ទន្លេអន្តរជាតិ | សំដៅដល់ទន្លេដែលមានភូមិសាស្ត្រពាក់ព័ន្ធដល់ទឹក ដី ប្រទេសចាប់ពីពីរឡើងទៅ។ |

## ជំពូកទី២
## គោលការណ៍នៃការគ្រប់គ្រងអាងទន្លេ

**មាត្រា៥ .-**

ដើម្បីគ្រប់គ្រងអាងទន្លេនៅក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យមានតុល្យភាព ប្រសិទ្ធភាព និងនិរន្តរភាព គោលការណ៍មួយចំនួនត្រូវបានកំណត់ដូចខាងក្រោម៖

- គ្រប់គ្រងប្រភពទឹកដើម្បីបម្រើដល់ការប្រើប្រាស់ ការអភិរក្ស និងការអភិវឌ្ឍធនធានទឹកនៅក្នុងអាងទន្លេ
- គ្រប់គ្រង អភិរក្ស និងអភិវឌ្ឍធនធានទឹកដោយឈរលើមូលដ្ឋាននៃទស្សនាទាន និងវិធីសាស្ត្រស្តីពីការគ្រប់គ្រងធនធានទឹកចម្រុះដោយអនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ
- គ្រប់គ្រងធនធានទឹកក្នុងអាងទន្លេ ដោយមិនគិតពីព្រំដែនរដ្ឋបាល និងស្ថិរភាពរវាងផ្នែកខាងលើនិងផ្នែកខាងក្រោមដោយឈរលើគោលការណ៍សមធម៌និងសង្គតិភាព
- រក្សាលំហូរទឹកអប្បបរមានៃផ្លូវទឹក និងនិរន្តរភាពកម្រិតកម្ពស់ទឹកក្រោមដី រួមចំណែកទ្រទ្រង់ដល់ប្រព័ន្ធអេកូឡូស៊ី
- គ្រប់គ្រងធនធានទឹកក្នុងអាងទន្លេអន្តរជាតិ ដោយឈរលើកិច្ចព្រមព្រៀងអន្តរជាតិ គោរពអធិបតេយ្យភាពជាតិ និងគោរពផលប្រយោជន៍គ្នាទៅវិញទៅមក
- អភិវឌ្ឍនិងប្រើប្រាស់ធនធានទឹកឱ្យមានសង្គតិភាពជាមួយនឹងធនធានធម្មជាតិដទៃទៀតដែលមាននៅក្នុងអាងទន្លេ
- បែងចែកការប្រើប្រាស់ទឹកប្រកបដោយប្រសិទ្ធភាពនិងសមភាព
- រួមចំណែកលើកស្ទួយកម្រិតជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋដោយគិតគូរលើបរិមាណនិងគុណភាពទឹក
- លើកទឹកចិត្តដល់ការអភិរក្សនិងការអភិវឌ្ឍធនធានទឹកក្នុងអាងទន្លេ
- សហការជាមួយប្រទេសជិតខាងក្នុងការប្រើប្រាស់ទឹកលើគ្រប់វិស័យ។

## ជំពូកទី៣
## ការកំណត់តំបន់អាងទន្លេ ដីចំណីមាត់ច្រាំង និងឆ្នេរ

**មាត្រា៦ .-**

យោងតាមលក្ខណៈភូមិសាស្ត្រនិងរបបជលសាស្ត្រ អាងទន្លេនៅក្នុងព្រះរាជាណាចក្រកម្ពុជាមាន ចំនួន៣៩(សាមសិបប្រាំបួន) ដែលត្រូវបានកំណត់ជា៧(ប្រាំពីរ)តំបន់។

ផែនទីកំណត់តំបន់អាងទន្លេនៅក្នុងព្រះរាជាណាចក្រកម្ពុជាមានចែងក្នុងឧបសម្ព័ន្ធទី១នៃអនុក្រឹត្យនេះ។

តារាងឈ្មោះនិងទំហំផ្ទៃអាងទន្លេនីមួយៗមានចែងក្នុងឧបសម្ព័ន្ធទី២នៃអនុក្រឹត្យនេះ។

**មាត្រា៧ .-**

ក្រសួងធនធានទឹកនិងឧតុនិយម ដោយមានការចូលរួមពីក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវរៀបចំធ្វើបញ្ជីសារពើភណ្ឌអាងទន្លេ រួមមានតំបន់ឆ្នេរ ទន្លេ ស្ទឹង ព្រែក បឹង អាងទឹក និងល្អាងទឹកក្រោមដី។ បញ្ជីសារពើភណ្ឌនេះបង្ហាញពីឈ្មោះ ទីតាំង ព្រំដែន បរិមាណ និងគុណភាពនៃធនធានទាំងនោះ។

បញ្ជីសារពើភណ្ឌអាងទន្លេត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងធនធានទឹកនិងឧតុនិយម។

**មាត្រា៨ .-**

ដីចំណីមាត់ច្រាំងនិងឆ្នេរនៃតំបន់អាងទន្លេត្រូវកំណត់ចម្ងាយដូចតទៅ៖

- ឆ្នេរនិងពាមសមុទ្រ ចម្ងាយ១០០(មួយរយ)ម៉ែត្រគិតពីមាត់ឆ្នេរនិងមាត់ពាម(ពេលទឹកជោរអតិបរមា)
- ទន្លេ ចម្ងាយ៥០(ហាសិប)ម៉ែត្រ គិតពីមាត់ច្រាំងទន្លេ
- ស្ទឹង ចម្ងាយ៣០(សាមសិប)ម៉ែត្រ គិតពីមាត់ច្រាំងស្ទឹង
- ព្រែក ចម្ងាយ២០(ម្ភៃ)ម៉ែត្រ គិតពីមាត់ច្រាំងព្រែក
- អូរ ចម្ងាយ១០(ដប់)ម៉ែត្រ គិតពីមាត់ច្រាំងអូរ
- ប្រឡាយមេ ចម្ងាយ១០(ដប់)ម៉ែត្រ គិតពីជើងទេរភ្លឺប្រឡាយផ្នែកខាងក្រៅ
- ប្រឡាយរង ចម្ងាយ៥(ប្រាំ)ម៉ែត្រ គិតពីជើងទេរភ្លឺប្រឡាយផ្នែកខាងក្រៅ
- ប្រឡាយស្រោចស្រព ចម្ងាយ៣(បី)ម៉ែត្រ គិតពីជើងទេរភ្លឺប្រឡាយផ្នែកខាងក្រៅ
- អាងទឹក ចម្ងាយ១០០(មួយរយ)ម៉ែត្រគិតពីក្រិតកម្ពស់ទឹកអតិបរមាដែលបានតម្កល់នៅក្នុងអាងទឹក
- បឹងបួ ចម្ងាយ៥០(ហាសិប)ម៉ែត្រគិតពីក្រិតកម្ពស់ទឹកអតិបរមាដែលបានតម្កល់នៅក្នុងអាងទឹក
- ទំនប់អាងទឹក ចម្ងាយ២០(ម្ភៃ)ម៉ែត្រ គិតពីជើងទេរផ្នែកខាងក្រោមទំនប់អាងទឹកដែលមានកម្ពស់តិចជាង៤(បួន)ម៉ែត្រ។ ចម្ងាយ១០០(មួយរយ)ម៉ែត្រ គិតពីជើងទេរផ្នែកខាងក្រោមទំនប់អាងទឹកដែលមានកម្ពស់ពី៤(បួន)ម៉ែត្រទៅ៨(ប្រាំបី)ម៉ែត្រ។ ក្នុងករណីទំនប់ដែលមានកម្ពស់លើសពី៨(ប្រាំបី)ម៉ែត្រឡើងទៅត្រូវបានកំណត់អនុក្រឹត្យដោយឡែក។

ដីចំណីមាត់ច្រាំង ឆ្នេរ និងពាមសមុទ្រនៅតំបន់រាជធានីឬក្រុងនៃខេត្តឬទីប្រជុំជន និងតំបន់អភិវឌ្ឍត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដោយឡែក។

ដីចំណីមាត់ច្រាំង ឆ្នេរ និងពាមសមុទ្រនៃតំបន់អាងទន្លេបានកំណត់ខាងលើជាសម្បត្តិសាធារណៈរបស់រដ្ឋ។

ការកំណត់ដីចំណីមាត់ច្រាំងនិងឆ្នេរខាងលើគ្មានអានុភាពប្រតិសកម្ម ពេលអនុក្រឹត្យនេះចូលជាធរមាន។

**មាត្រា៩ .-**

ស្ថានភាពបច្ចុប្បន្ននិងហានិភ័យចំពោះធនធានទឹកក្នុងអាងទន្លេ ត្រូវបានធ្វើចំណាត់ថ្នាក់ជា៣(បី)កម្រិត ដូចខាងក្រោម៖

**- កម្រិត១ :** ធនធានទឹកដែលទទួលរងហានិភ័យដោយមិនបង្កផលប៉ះពាល់ខូចខាតធ្ងន់ធ្ងរដល់អាយុជីវិតមនុស្ស សត្វ រុក្ខជាតិ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត។

- **កម្រិត២** ៖ ធនធានទឹកដែលទទួលរងហានិភ័យដោយបង្កផលប៉ះពាល់ ខូចខាត និងគំរាមកំហែង ជាយថាហេតុក្នុងរយៈពេលខ្លីដល់អាយុជីវិតមនុស្ស សត្វ រុក្ខជាតិ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត
- **កម្រិត៣** ៖ ធនធានទឹកដែលរងហានិភ័យដោយបង្កមហន្តរាយធ្ងន់ធ្ងរ និងយូរអង្វែងដល់អាយុជីវិតមនុស្ស សត្វ រុក្ខជាតិ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត។

ចំណាត់ថ្នាក់ហានិភ័យត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងធនធានទឹកនិងឧតុនិយម។

## ជំពូកទី៤
## សមត្ថកិច្ចនិងយន្តការនៃការគ្រប់គ្រងអាងទន្លេ

**មាត្រា១០.-**

ក្រសួងធនធានទឹកនិងឧតុនិយម ជាស្ថាប័នមានសមត្ថកិច្ចដឹកនាំ ត្រួតពិនិត្យ និងសម្របសម្រួល ក្នុងការគ្រប់គ្រង ការការពារ ការអភិរក្ស និងការអភិវឌ្ឍអាងទន្លេ ស្របតាមស្មារតីនៃច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា១១.-**

ដើម្បីគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍអាងទន្លេនៅក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យមានប្រសិទ្ធភាព និងនិរន្តរភាព ត្រូវរៀបចំយន្តការដូចខាងក្រោម៖

១- រៀបចំបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងអាងទន្លេ។

២- រៀបចំបង្កើតគណៈកម្មាធិការរាជធានី ខេត្តគ្រប់គ្រងអាងទន្លេ។

**មាត្រា១២.-**

គណៈកម្មាធិការជាតិគ្រប់គ្រងអាងទន្លេ មានសមាសភាពដូចតទៅ៖

| | |
|---|---|
| ១- រដ្ឋមន្ត្រីក្រសួងធនធានទឹកនិងឧតុនិយម | ប្រធាន |
| ២- រដ្ឋលេខាធិការក្រសួងមហាផ្ទៃ១រូប | អនុប្រធាន |
| ៣- រដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន១រូប | អនុប្រធាន |
| ៤- រដ្ឋលេខាធិការក្រសួងធនធានទឹកនិងឧតុនិយម១រូប | អនុប្រធានអចិន្ត្រៃយ៍ |
| ៥- រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី១រូប | សមាជិក |
| ៦- រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ១រូប | សមាជិក |
| ៧- រដ្ឋលេខាធិការក្រសួងបរិស្ថាន១រូប | សមាជិក |
| ៨- រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ១រូប | សមាជិក |
| ៩- រដ្ឋលេខាធិការក្រសួងឧស្សាហកម្មនិងសិប្បកម្ម១រូប | សមាជិក |
| ១០- រដ្ឋលេខាធិការក្រសួងរ៉ែនិងថាមពល១រូប | សមាជិក |
| ១១- រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ១រូប | សមាជិក |
| ១២- រដ្ឋលេខាធិការក្រសួងទេសចរណ៍១រូប | សមាជិក |
| ១៣- រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់១រូប | សមាជិក |
| ១៤- រដ្ឋលេខាធិការក្រសួងផែនការ១រូប | សមាជិក |
| ១៥- រដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ១រូប | សមាជិក |
| ១៦- រដ្ឋលេខាធិការក្រសួងសុខាភិបាល១រូប | សមាជិក |
| ១៧- តំណាងគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា១រូប | សមាជិក |

សមាសភាពជាក់ស្តែងនៃគណៈកម្មាធិការជាតិគ្រប់គ្រងអាងទន្លេត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**មាត្រា១៣ ..**

គណៈកម្មាធិការជាតិគ្រប់គ្រងអាងទន្លេមានតួនាទីនិងភារកិច្ច ដូចខាងក្រោម៖

- រៀបចំគោលការណ៍ណែនាំដល់គណៈកម្មាធិការរាជធានី ខេត្តគ្រប់គ្រងអាងទន្លេក្នុងការរៀបចំផែនការមេ ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់ការគ្រប់គ្រង ការការពារ ការអភិរក្ស និងការអភិវឌ្ឍអាងទន្លេស្របតាមគោលនយោបាយជាតិនិងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិលើវិស័យធនធានទឹក ព្រមទាំងអនុម័តលើផែនការទាំងនោះ
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តផែនការមេ ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់ការគ្រប់គ្រង ការការពារ ការអភិរក្ស និងការអភិវឌ្ឍអាងទន្លេ
- សម្របសម្រួលក្នុងការពិគ្រោះយោបល់ជាមួយនឹងអ្នកពាក់ព័ន្ធដែលអាស្រ័យផលពីធនធានទឹកក្នុងអាងទន្លេលើការរៀបចំផែនការមេ ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់ការគ្រប់គ្រង ការការពារ ការអភិរក្ស និងការអភិវឌ្ឍអាងទន្លេ
- ជូនដំណឹងឱ្យបានទាន់ពេលវេលាដល់ប្រជាជនក្នុងមូលដ្ឋានអំពីសកម្មភាពនានាដែលទាក់ទងនឹងទឹក
- សម្របសម្រួលនិងដោះស្រាយវិវាទនានានៅក្នុងការគ្រប់គ្រង ការការពារ ការអភិរក្ស និងការអភិវឌ្ឍអាងទន្លេ
- រក្សាទុកឯកសារ និងព័ត៌មាននានាស្តីពីបញ្ហា និងសកម្មភាពធនធានទឹកក្នុងអាងទន្លេ
- សហការជាមួយនឹងក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍពាក់ព័ន្ធដើម្បីសិក្សានិងស្រាវជ្រាវទាក់ទងនឹងការរៀបចំផែនការមេ ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់ការគ្រប់គ្រង ការការពារ ការអភិរក្ស និងការអភិវឌ្ឍអាងទន្លេ
- រៀបចំរបាយការណ៍ប្រចាំឆ្នាំជូនរាជរដ្ឋាភិបាល
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលរាជរដ្ឋាភិបាលប្រគល់ជូន។

**មាត្រា១៤ ..**

គណៈកម្មាធិការជាតិគ្រប់គ្រងអាងទន្លេត្រូវប្រជុំយ៉ាងតិច១(មួយ)ដង ក្នុងមួយឆ្នាំតាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីប្រធានអវត្តមាន ប្រធានត្រូវផ្ទេរសិទ្ធិជូនអនុប្រធានដើម្បីដឹកនាំអង្គប្រជុំ។

ក្នុងករណីចាំបាច់ ប្រធានអាចអញ្ជើញតំណាងមកពីក្រសួង ស្ថាប័នផ្សេងៗ មន្ត្រីជំនាញ អ្នកបច្ចេកទេស ឬតំណាងវិស័យឯកជន ដើម្បីចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់ឬការស្រាវជ្រាវបញ្ហាទាក់ទងនឹងសកម្មភាពពាក់ព័ន្ធការគ្រប់គ្រងអាងទន្លេ។

**មាត្រា១៥ ..**

គណៈកម្មាធិការជាតិគ្រប់គ្រងអាងទន្លេមានលេខាធិការដ្ឋានមួយ ដែលមានទីតាំងនៅក្នុងក្រសួងធនធានទឹកនិងឧតុនិយមសម្រាប់កិច្ចដំណើរការសកម្មភាពរបស់ខ្លួន។

គណៈកម្មាធិការជាតិគ្រប់គ្រងអាងទន្លេមានសិទ្ធិប្រើត្រារបស់ក្រសួងធនធានទឹកនិងឧតុនិយម។

លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគ្រប់គ្រងអាងទន្លេ ដឹកនាំដោយប្រធានលេខាធិការដ្ឋានមួយរូបនិងមានអនុប្រធានលេខាធិការដ្ឋានមួយចំនួនតាមការចាំបាច់។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគ្រប់គ្រងអាងទន្លេត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងធនធានទឹកនិងឧតុនិយម។

**មាត្រា១៦ .-**

គណៈកម្មាធិការរាជធានី ខេត្តគ្រប់គ្រងអាងទន្លេមានសមាសភាពដូចតទៅៈ

- អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត — ប្រធាន
- អភិបាលរងរាជធានី ខេត្ត — អនុប្រធាន
- ប្រធានមន្ទីរធនធានទឹកនិងឧតុនិយម — សមាជិកអចិន្ត្រៃយ៍
- ប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ — សមាជិក
- ប្រធានមន្ទីរកសិកម្ម — សមាជិក
- ប្រធានមន្ទីរបរិស្ថាន — សមាជិក
- ប្រធានមន្ទីរសាធារណការនិងដឹកជញ្ជូន — សមាជិក
- ប្រធានមន្ទីរឧស្សាហកម្មនិងសិប្បកម្ម — សមាជិក
- ប្រធានមន្ទីររ៉ែនិងថាមពល — សមាជិក
- ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទ — សមាជិក
- ប្រធានមន្ទីរទេសចរណ៍ — សមាជិក
- ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី — សមាជិក
- ប្រធានមន្ទីរផែនការ — សមាជិក
- នាយខណ្ឌរដ្ឋបាលព្រៃឈើ — សមាជិក
- នាយខណ្ឌរដ្ឋបាលជលផល — សមាជិក
- អភិបាលស្រុក ខណ្ឌ ក្រុង មេឃុំ ចៅសង្កាត់ដែលមានការពាក់ព័ន្ធ — សមាជិក។

ក្នុងករណីចាំបាច់ ប្រធានគណៈកម្មាធិការអាចអញ្ជើញមន្ត្រីជំនាញ ឬបុគ្គលដែលតំណាងឱ្យសហគមន៍ផ្សេងៗទៀត ដែលបានទទួលផលក្នុងអាងទន្លេឱ្យចូលរួមជាអ្នកសង្កេតការណ៍នៅក្នុងកិច្ចប្រជុំគណៈកម្មាធិការខាងលើ។

សមាសភាពជាក់ស្តែងនៃគណៈកម្មាធិការរាជធានី ខេត្តគ្រប់គ្រងអាងទន្លេ ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់ប្រធានគណៈកម្មាធិការរាជធានី ខេត្តគ្រប់គ្រងអាងទន្លេ។

**មាត្រា១៧ .-**

គណៈកម្មាធិការរាជធានី ខេត្តគ្រប់គ្រងអាងទន្លេ ត្រូវមានលេខាធិការដ្ឋានមួយដើម្បីធានាដល់កិច្ចដំណើរការឱ្យមានប្រសិទ្ធភាពខ្ពស់និងអាចប្រើត្រាដោយឡែករបស់ខ្លួន។ លេខាធិការដ្ឋានមានទីតាំងស្ថិតនៅក្នុងមន្ទីរធនធានទឹកនិងឧតុនិយមរាជធានី ខេត្តដែលមានអភិបាលនៃគណៈអភិបាលរាជធានី ខេត្តជាប្រធានគណៈកម្មាធិការរាជធានី ខេត្តគ្រប់គ្រងអាងទន្លេ។ ប្រធានមន្ទីរធនធានទឹកនិងឧតុនិយមរាជធានី ខេត្ត នេះជាប្រធានលេខាធិការដ្ឋាន។

គណៈកម្មាធិការរាជធានី ខេត្តគ្រប់គ្រងអាងទន្លេត្រូវកោះប្រជុំយ៉ាងតិច២(ពីរ)ដងក្នុងមួយឆ្នាំ។ ក្នុងករណីចាំបាច់ អាចកោះប្រជុំជាវិសាមញ្ញបាន។

ប្រធានគណៈកម្មាធិការរាជធានី ខេត្តគ្រប់គ្រងអាងទន្លេ ត្រូវរាយការណ៍ពីលទ្ធផលនៃកិច្ចប្រជុំនិងសកម្មភាពការងារប្រចាំឆ្នាំជូនប្រធានគណៈកម្មាធិការជាតិគ្រប់គ្រងអាងទន្លេ។

**មាត្រា១៨ .-**

គណៈកម្មាធិការរាជធានី ខេត្តគ្រប់គ្រងអាងទន្លេមានតួនាទីនិងភារកិច្ចដូចតទៅ៖

- រៀបចំបទបញ្ញាផ្ទៃក្នុង និងផែនការសកម្មភាពសម្រាប់ការគ្រប់គ្រង ការអភិរក្ស ការបែងចែកទឹក ការស្តារឡើងវិញ និងការអភិវឌ្ឍអាងទន្លេស្របតាមគោលនយោបាយជាតិលើវិស័យធនធានទឹក
- បញ្ជូនរាល់ផែនការទៅគណៈកម្មាធិការជាតិគ្រប់គ្រងអាងទន្លេ ដើម្បីពិនិត្យនិងសម្រេច
- តាមដាននិងសម្របសម្រួលរាល់សកម្មភាពទាំងអស់របស់ក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការអនុវត្តផែនការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍអាងទន្លេ
- បន្តណែនាំអំពីវិធានការសម្រាប់ការពារបរិស្ថានទឹក ការធ្វើអាជីវកម្ម ការប្រើប្រាស់និងការអភិវឌ្ឍធនធានទឹក និងវិធានការសម្រាប់បង្ការហានិភ័យ និងការកាត់បន្ថយគ្រោះអាសន្នដែលបង្កដោយទឹកក្នុងអាងទន្លេ
- បន្តណែនាំអំពីវិធានការដល់ភ្នាក់ងារជំនាញ ដើម្បីឆ្លើយតបនឹងសកម្មភាពនានា ដែលបំពុលបរិស្ថានទឹក
- ជូនដំណឹងដល់ប្រជាពលរដ្ឋដែលរស់នៅក្នុងអាងទន្លេឱ្យបានទាន់ពេលវេលាអំពីគ្រោះអាសន្នបណ្តាលមកពីទឹក
- សម្របសម្រួលនិងដោះស្រាយរាល់ទំនាស់នានាក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលគណៈកម្មាធិការជាតិគ្រប់គ្រងអាងទន្លេប្រគល់ជូន។

**មាត្រា១៩ .-**

លេខាធិការដ្ឋាននៃគណៈកម្មាធិការរាជធានី ខេត្តគ្រប់គ្រងអាងទន្លេមានតួនាទីនិងភារកិច្ចដូចតទៅ៖

១- ផ្តល់ការគាំទ្រផ្នែករដ្ឋបាលនិងការសម្របសម្រួលផ្នែកហិរញ្ញវត្ថុដល់គណៈកម្មាធិការរាជធានី ខេត្តគ្រប់គ្រងអាងទន្លេក្នុងការរៀបចំផែនការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍអាងទន្លេ។

២- សម្របសម្រួលក្នុងការប្រមូលព័ត៌មាន ការចងក្រងប្រព័ន្ធទិន្នន័យ និងការរៀបចំរបាយការណ៍ជូនគណៈកម្មាធិការរាជធានី ខេត្តគ្រប់គ្រងអាងទន្លេ។

៣- តាមដាននិងត្រួតពិនិត្យការអនុវត្តសេចក្តីសម្រេចនានា ដែលបានដាក់ចេញដោយគណៈកម្មាធិការរាជធានី ខេត្តគ្រប់គ្រងអាងទន្លេ។

៤-ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលគណៈកម្មាធិការរាជធានី ខេត្តគ្រប់គ្រងអាងទន្លេប្រគល់ជូន។

**មាត្រា២០ .-**

គណៈកម្មាធិការជាតិគ្រប់គ្រងអាងទន្លេនិងគណៈកម្មាធិការរាជធានី ខេត្តគ្រប់គ្រងអាងទន្លេត្រូវមានថវិកាសម្រាប់ដំណើរការរដ្ឋបាល។ ថវិកានេះត្រូវស្ថិតក្នុងកញ្ចប់ថវិកាប្រចាំឆ្នាំរបស់ក្រសួងធនធានទឹកនិងឧតុនិយមនិងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍ។

## ជំពូកទី៥
## ផែនការគ្រប់គ្រងអាងទន្លេ

**មាត្រា២១ .-**

គណៈកម្មាធិការជាតិគ្រប់គ្រងអាងទន្លេត្រូវរៀបចំផែនការមេ ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់ការគ្រប់គ្រង ការការពារ ការអភិរក្ស និងការអភិវឌ្ឍអាងទន្លេឱ្យស្របនឹងគោលនយោបាយជាតិ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងកម្មវិធីវិនិយោគសាធារណៈរបស់រាជរដ្ឋាភិបាល។

ក្នុងការរៀបចំផែនការមេ ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់ការគ្រប់គ្រង ការការពារ ការអភិរក្ស និងការអភិវឌ្ឍអាងទន្លេ គណៈកម្មាធិការជាតិគ្រប់គ្រងអាងទន្លេត្រូវចាត់ឱ្យមានការពិគ្រោះយោបល់យ៉ាងទូលំទូលាយពីក្រសួង ស្ថាប័នពាក់ព័ន្ធ គណៈកម្មាធិការរាជធានី ខេត្តគ្រប់គ្រងអាងទន្លេ ដៃគូអភិវឌ្ឍ និងអ្នកពាក់ព័ន្ធ ហើយអនុម័តលើផែនការមេ ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពទាំងនេះដើម្បីធ្វើការបោះពុម្ពផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធនានា។

**មាត្រា២២ .-**

ការរៀបចំផែនការមេ ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់ការគ្រប់គ្រង ការការពារ ការអភិរក្ស និងការអភិវឌ្ឍអាងទន្លេ ត្រូវពិនិត្យពិចារណាដោយឈរលើគោលការណ៍ដូចមានចែងក្នុងមាត្រា៥នៃអនុក្រឹត្យនេះ។

**មាត្រា២៣ .-**

អាណត្តិរបស់ផែនការមេមានសុពលភាពពី១០(ដប់)ទៅ១៥(ដប់ប្រាំ)ឆ្នាំ គិតចាប់ពីថ្ងៃទទួលបានការអនុម័តពីគណៈកម្មាធិការជាតិគ្រប់គ្រងអាងទន្លេ។

អាណត្តិរបស់ផែនការយុទ្ធសាស្ត្រមានសុពលភាពពី៣(បី)ទៅ៥(ប្រាំ)ឆ្នាំ គិតចាប់ពីថ្ងៃទទួលបានការអនុម័តពីគណៈកម្មាធិការជាតិគ្រប់គ្រងអាងទន្លេ។

អាណត្តិរបស់ផែនការសកម្មភាពមានសុពលភាពពី១(មួយ)ទៅ៣(បី)ឆ្នាំ គិតចាប់ពីថ្ងៃទទួលបានការអនុម័តពីគណៈកម្មាធិការជាតិគ្រប់គ្រងអាងទន្លេ។

គណៈកម្មាធិការជាតិគ្រប់គ្រងអាងទន្លេត្រូវដឹកនាំ សម្របសម្រួល ត្រួតពិនិត្យ តាមដាន និងវាយតម្លៃលើការអនុវត្តផែនការគ្រប់គ្រងអាងទន្លេ រៀងរាល់ឆមាសនៃឆ្នាំនីមួយៗ។

ក្នុងករណីដែលការអនុវត្តផែនការគ្រប់គ្រងអាងទន្លេដំណើរការបានល្អ គណៈកម្មាធិការជាតិគ្រប់គ្រងអាងទន្លេអាចពន្យារសុពលភាពបន្តបាន ប៉ុន្តែមិនត្រូវលើសពី៥(ប្រាំ)ឆ្នាំ គិតពីថ្ងៃដែលអាណត្តិរបស់ផែនការគ្រប់គ្រងអាងទន្លេអស់សុពលភាព។ រាល់ផែនការមេ ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់ការគ្រប់គ្រង ការការពារ ការអភិរក្ស និងការអភិវឌ្ឍអាងទន្លេណាមួយដែលពិនិត្យឃើញថា មិនអាចអនុវត្តបន្តទៅមុខបាន គណៈកម្មាធិការជាតិគ្រប់គ្រងអាងទន្លេត្រូវណែនាំឱ្យរៀបចំកែសម្រួលជាថ្មីឡើងវិញ ស្របតាមកាលានុវត្តភាព។

នីតិវិធីនៃការរៀបចំផែនការមេ ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់ការគ្រប់គ្រង ការការពារ ការអភិរក្ស និងការអភិវឌ្ឍអាងទន្លេត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម។

## ជំពូកទី៦
## វិធានការគ្រប់គ្រងអាងទន្លេ

**មាត្រា២៤ .-**

វិធានការសំខាន់ៗសម្រាប់គ្រប់គ្រងអាងទន្លេមានការគ្រប់គ្រងបរិមាណនិងគុណភាពទឹក ការការពារប្រភពទឹក ការបង្ការនិងកាត់បន្ថយគ្រោះអាសន្នបង្កឡើងដោយទឹក។

គណៈកម្មាធិការជាតិគ្រប់គ្រងអាងទន្លេ ត្រូវរៀបចំសៀវភៅណែនាំលម្អិតស្តីពីគោលការណ៍ និងវិធានការនៃការគ្រប់គ្រងអាងទន្លេ។

**មាត្រា២៥ .-**

គណៈកម្មាធិការជាតិគ្រប់គ្រងអាងទន្លេនិងគណៈកម្មាធិការរាជធានី ខេត្តគ្រប់គ្រងអាងទន្លេ ត្រូវរៀបចំអនុវត្តការត្រួតពិនិត្យនិងការវាយតម្លៃធនធានទឹក និងធនធានពាក់ព័ន្ធ។

សកម្មភាពសម្រាប់ត្រួតពិនិត្យនិងការវាយតម្លៃធនធានទឹក និងធនធានពាក់ព័ន្ធនៅក្នុងអាងទន្លេ រួមមាន៖

- ធ្វើអង្កេតនិងធ្វើបញ្ជីសារពើភណ្ឌធនធានទឹក ដោយផ្តោតទៅលើបរិមាណនិងគុណភាពទឹកលើដីនិងក្រោមដីក្នុងអាងទន្លេនីមួយៗ

- ធ្វើអង្កេតអំពីបរិស្ថានពាក់ព័ន្ធនឹងធនធានទឹកក្នុងអាងទន្លេ ដោយគិតបញ្ចូលទាំងការត្រួតពិនិត្យអំពីផលប៉ះពាល់ដែលអាចកើតមានឡើងពីការប្រែប្រួលអាកាសធាតុ

- រៀបចំចងក្រងទិន្នន័យនិងព័ត៌មានដោយធ្វើផែនទីស្តីពីស្ថានភាពអាងទន្លេ ផែនទីអភិរក្សធនធានទឹក ផែនទីទឹកក្រោមដី រួមទាំងផែនទីតំបន់ប្រភពទឹកសម្រាប់បំពេញទឹកក្រោមដីឡើងវិញ

- រៀបចំបញ្ជីកំណត់ទីតាំងធនធានទឹកដែលរងការបំពុល ការថយចុះបរិមាណ គុណភាព និងការធ្វើអាជីវកម្មទឹកហួសកម្រិត

- ជូនដំណឹងជាមុនអំពីព្រឹត្តិការណ៍នានាដែលពាក់ព័ន្ធនឹងធនធានទឹក អង្កេតអំពីស្ថានភាពបច្ចុប្បន្ននៃការធ្វើអាជីវកម្មទឹក ការប្រើប្រាស់ធនធានទឹក និងការបង្ហូរទឹកសំណល់ចូលប្រភពទឹកក្នុងអាងទន្លេ

- បង្កើតនិងរក្សាទុកនូវប្រព័ន្ធព័ត៌មាននិងមូលដ្ឋានទិន្នន័យ។

## ជំពូកទី៧
## អវសានប្បញ្ញត្តិ

**មាត្រា២៦ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា២៧ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងធនធានទឹកនិងឧតុនិយម រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល** :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធទី១នៃអនុក្រឹត្យលេខ ៩៨ អនក្រ.បក
ចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ២០១៥ ស្តីពីការគ្រប់គ្រងអាងទន្លេ

# ផែនទីកំណត់តំបន់អាងទន្លេនៅក្នុងព្រះរាជាណាចក្រកម្ពុជា



**ឧបសម្ព័ន្ធទី២នៃអនុក្រឹត្យលេខ ៩៨ អនក្រ.បក**
**ចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ២០១៥ ស្តីពីការគ្រប់គ្រងអាងទន្លេ**

# តារាងឈ្មោះនិងទំហំផ្ទៃអាងទន្លេនីមួយៗ

| ល.រ. | លេខកូដអាងទន្លេ | ឈ្មោះទន្លេ | ផ្ទៃអាងទន្លេ គម$^{២}$ |
|---|---|---|---|
| **១. តំបន់មាត់សមុទ្រ** | | | |
| ១ | ១ | ព្រែកកំពង់បាយ | ៣ ០១៨ |
| ២ | ២ | ព្រែកទឹកសាប | ១ ៥២៩ |
| ៣ | ៣ | ព្រែកស្រែអំបិល | ២ ៦៥៣ |
| ៤ | ៤ | ព្រែកអណ្តូងទឹក | ២ ៤៦០ |
| ៥ | ៥ | ព្រែកត្រពាំងរូង | ២ ៦១៥ |
| ៦ | ៦ | ព្រែកតាតៃ | ១ ៦១៩ |
| ៧ | ៧ | ព្រែកកោះប៉ោ | ៣ ១០៩ |
| ៨ | ៨ | ស្ទឹងមេទឹក | ១ ០៤៣ |
| | | **សរុប ១** | ១៨ ០៤៥ |
| **២. តំបន់ទន្លេបាសាក់** | | | |
| ៩ | ៩ | ស្ទឹងតន់ហាន់ | ១ ៧៦៥ |
| ១០ | ១០ | ស្ទឹងស្លាគូ | ២ ៤៨៥ |
| ១១ | ១១ | ស្ទឹងព្រែកត្នោត | ៧ ០៥៥ |
| | | **សរុប ២** | ១១ ៣០៥ |
| **៣. តំបន់ទន្លេសាប** | | | |
| ១២ | ១២ | ស្ទឹងក្រាំងពន្លៃ | ៣ ០៣៣ |
| ១៣ | ១៣ | ស្ទឹងបរិបូណ៌ | ៣ ០០៣ |
| ១៤ | ១៤ | ស្ទឹងបំណាក់ | ១ ១១៦ |
| ១៥ | ១៥ | ស្ទឹងពោធិ៍សាត់ | ៥ ៩៦៤ |
| ១៦ | ១៦ | ស្ទឹងស្វាយដូនកែវ | ២ ២២៨ |
| ១៧ | ១៧ | ស្ទឹងមោងឫស្សី ស្ទឹងដូនទ្រី | ១ ៤៦៨ |
| ១៨ | ១៨ | ស្ទឹងសង្កែ | ៦ ០៥២ |
| ១៩ | ១៩ | ស្ទឹងមង្គលបុរី | ៥ ២៦៤ |
| ២០ | ២០ | ស្ទឹងសិរីសោភ័ណ | ៥ ៥៩៣ |
| ២១ | ២១ | ស្ទឹងស្រែង | ៩ ៩៣១ |
| ២២ | ២២ | ស្ទឹងសៀមរាប | ៣ ៦១៩ |

| | | | |
|---|---|---|---|
| ២៣ | ២៣ | ស្ទឹងជីក្រែង | ២ ៧១៤ |
| ២៤ | ២៤ | ស្ទឹងស្មោង | ៤ ៣៥៧ |
| ២៥ | ២៥ | ស្ទឹងសែន | ១៦ ៣៤២ |
| ២៦ | ២៦ | ស្ទឹងជីនិត | ៨ ២៣៦ |
| ២៧ | ៣៩ | បឹងទន្លេសាប | ២ ៧៤៣ |
| | | **សរុប ៣** | ៨១ ៦៦៣ |
| **៤. តំបន់ទន្លេភាគឦសាន** | | | |
| ២៨ | ២៧ | ទន្លេសេកុង | ៥ ៥៦៤ |
| ២៩ | ២៨ | ទន្លេសេសាន | ៧ ៦២១ |
| ៣០ | ២៩ | ទន្លេស្រែពក | ១២ ៧៨០ |
| ៣១ | ៣០ | ព្រែកព្រះ | ២ ៣៩៩ |
| ៣២ | ៣១ | ព្រែកក្រៀង | ៣ ៣៣១ |
| ៣៣ | ៣២ | ព្រែកកាំពីរ | ១ ១៤២ |
| ៣៤ | ៣៣ | ព្រែកទេរ | ៤ ៣៦៣ |
| ៣៥ | ៣៤ | ព្រែកឆ្លូង | ៥ ៥៩៩ |
| | | **សរុប ៤** | ៤២ ៨០០ |
| **៥. តំបន់មេគង្គលើ(កម្ពុជា)** | | | |
| ៣៦ | ៣៥ | ដៃស្ទឹង ព្រែកទន្លេមេគង្គលើ (Mekong Riverine) | ១០ ៣៧៣ |
| | | **សរុប ៥** | ១០ ៣៧៣ |
| **៦. តំបន់ភាគអាគ្នេយ៍** | | | |
| ៣៧ | ៣៦ | ទន្លេវ៉ៃគោ | ៦ ៦១៨ |
| | | **សរុប ៦** | ៦ ៦១៨ |
| **៧. តំបន់ដីសណ្ដមេគង្គក្រោម** | | | |
| ៣៨ | ៣៧ | មេគង្គដីសណ្ដកម្ពុជា (Mekong Delta Cambodia) | ៨ ៧២៣ |
| ៣៩ | ៣៨ | តំបន់លិចទឹកទន្លេមេគង្គ ទន្លេសាប (ស្ពានត្រស់) | ១ ៥០៨ |
| | | **សរុប ៧** | ១០ ២៣១ |
| | | **សរុបរួម** | ១៨១ ០៣៥ |

**Unofficial translation**

# Kingdom of Cambodia

Nation Religion King

Royal Government of Cambodia
No. 98 ank/bk

# Sub-Decree
# On
# River Basin Management

## The Royal Government

Pursuant to:

- The Constitution of Kingdom of Cambodia;
- Royal Decree No. ns/rkt/0913/903, dated 24 September, 2013, on the appointment of Royal Government of the Kingdom of Cambodia;
- Royal Code No. 02/ns/94, dated July 20, 1994, promulgating the Law on Organization and Functioning of the Council of Ministers;
- Royal Code No. ns/rkm/0699/08, dated June 23, 1999, promulgating the Law on the Establishment of the Ministry of Water Resources and Meteorology;
- Royal Code No. ns/rkm/0607/016, dated June 29, 2007, promulgating the Law on the Management of Water Resources in the Kingdom of Cambodia;
- Sub-Decree No. 58 ank/bk dated June 30, 1999, on the Organization and Functioning of the Ministry of Water Resources and Meteorology;
- Approval by the Council of Ministers during its plenary meeting session held on 10 July, 2015;

## IT IS HEREBY DECIDED

## Chapter 1
## General Provisions

**Article 1:**

The objective of this Sub-Decree is to regulate the management, conservation and development of the river basins in an effective and sustainable manner as stated in the Law on Water Resources Management in the Kingdom of Cambodia.

**Article 2:**

The goal of this Sub-Decree is to set out the procedures for the establishment and implementation of the plans for the management, conservation and development of the river basin, sub-river basin, watershed, ground water and aquifer.

**Article 3:**

This Sub-Decree shall cover all river basins in the Kingdom of Cambodia.

**Article 4:**

The definitions of key terms used in this sub-decree have the following meaning:

- **River Basin**: is an a geographical area within a catchment where the surface and ground water sources naturally run into a river and flow out at a common point or into the area;
- **Sub-river basin**: is a part of a river basin;
- **Groundwater**: means the underground water flowing through soil particles and cracks in rocks undergrounds;
- **Aquifer**: means any geological formation containing storing or conducting groundwater from which the water can be extracted;
- **Sea**: is the salty water source which receives water flows from rivers, streams, canals, groundwater and from upper catchments;
- **River**: is a natural waterway whose sources are from stream, canals, torrents, groundwater and upper catchments which flow to the sea;
- **Stream**: is a natural waterway whose sources are from torrents, canals and groundwater and upper catchments which flow to lakes and sea;
- **Small stream**: is a natural or artificial waterway which convey waters in or out from the river or stream and upper catchment;
- **Valley**: is water natural stream or fall created by natural phenomena due to erosion by water from the higher slopes;
- **Lake**: is a considerable inland water body or an expanded part of a river formed by slopes or natural deep that may or may not have water depending on the season, and whose sources are from catchment, rivers, stream or small stream;
- **Reservoir**: is natural or artificial water body from which water can be used;
- **Sea, River and Stream Shore**: is the land or sand slope areas which be occasionally flooded;
- **Bank of river, stream, canal, lake and reservoir**: portion land which normally flooded in the river, stream, canal and reservoir, excluding land, rock and other elements which are located far from the bank and occasionally flooded;
- **Shore line**: is the line which limited the highest height of water in wet season, except in the abnormal flood event;
- **Sea shore**: is the highest water line of the shore;
- **Estuary**: is the area where the last part of the river, stream, or small stream flows into the sea;

- **Minimum Flow**: is a necessary flow regime that needs to be maintained in the river, stream, canal, for the sustainability of the ecology and other advantages;
- **Risky zone**: is river basins, sub-river basins, groundwater, aquifers which have been considered as affected or damaged by development and other uses;
- **International river**: is the river which geographically flows through two or more countries;

## Chapter 2
## Principles of river basin management

**Article 5:**

For the management of river basins in the Kingdom of Cambodia in a balance, sustainable and effective manner, the overall principles have been determined as follows:

- To manage water sources to serve the use, conservation and development of water resources in the river basin;
- To manage, conserve and develop water resources based on integrated water resources management (IWRM) concepts and approaches in accordance with the Law on Water Resources Management, and enhanced resilience to climate change;
- To manage water resources in the river basin in a unified manner across administrative boundaries, recognizing upstream and downstream linkages, and based on equity and harmony.
- To ensure minimum flows on watercourses to support water related ecological systems and ensure community values;
- To manage water resources in international river basin, based on international agreements, ensuring territorial sovereignty and national mutual interest;
- To develop and use water resources in harmony with other natural resources available in the basin;
- To allocate the use of water in an effective and equitable manner;
- To promote people’s livelihood ensuring their access to water, both quantity and quality;
- To encourage the conservation and development of water resources in the river basin and
- To cooperate with neighboring countries in the of water for all fields.

## Chapter 3
## River Basin Zoning and delineation of riparian land

**Article 6:**

Based on geographical and hydrological conditions in the Kingdom of Cambodia, there are 39 (thirty nine) river basins which are grouped into 07 (seven) hydrological zones.

A map showing the river basins within the Kingdom of Cambodia is attached as Annex I of this Sub-Decree.

A list of river basins and catchment areas is attached hereto as Annex II.

**Article 7:**

The Ministry of Water Resources and Meteorology shall, with the participation of the Ministries, institutions, and local government, prepare inventories of the river basins including estuaries, rivers, streams, lakes, reservoirs and aquifers. in the Kingdom of Cambodia. This inventory shall include the names, locations, demarcation, boundary, quantity and quality of those resources.

The river basin inventory shall be set out by a Prakas of the Ministry of Water Resources and Meteorology.

**Article 8:**

The distance of riparian and coastal strips along key natural water features and water works in rural areas of river basins is defined below:

| | |
|---|---|
| - Coastal strip and estuary | 100 (one hundred) meters from the coastal bank and estuary bank |
| - River | 50 (fifty) meters from its bank |
| - Stream | 30 (thirty) meters from its bank |
| - Creek | 20 (twenty) meters from its bank |
| - Small stream | 10 (ten) meters from its bank |
| - Main channel | 10 (ten) meters from the terrace of channel embankment |
| - Distribution channel | 05 (five) meters from the terrace of channel embankment |
| - Irrigation channel | 03 (three) meters from the terrace of channel embankment |
| - Basin area | 100 (one hundred) meters from the maximum water level from the basin water surface |
| - Lakes | 50(fifty) meters from the maximum water level allocated in the reservoir |
| - Basin embankment | 20 (twenty) meters from the terrace beneath the basin embankment of less than 04 (four); 100 (one hundred) meters from the terrace between 4 to 8 meters high. In case the embankment height exceeds 08 (eight) meters high, it shall be determined by separate sub-decree. |

The distances of riparian and coastal strips along key natural water features within cities or towns of the provinces or populous areas and development areas shall be set out by a separate sub-decree and legal documents.

The riparian land as above stated is the state's public asset.

The delineation of riparian land has no retroactivity on existing land with ownership titles issued before this sub-decree is in force.

**Article 9:**

The current status of and risks to water resources in the river basin are classified into three categories as follows:

Level 1: water resources which has been affected by risks, causing no significant harm to the lives of people, animals, plants and physical infrastructures;

Level 2: water resources, which has been affected by risks and eventually cause damage, destruction and threat to the lives of people, animals and plants in the foreseeable future;

Level 3: water resources, which have been affected by risks and severely cause immediate and long term damage and impacts to the lives of people, animals, plants and physical infrastructures.

The three categories of risks to water sources shall be defined in detail by a Prakas by MOWRAM.

## Chapter 4
## Jurisdiction, Mechanism and Committee for River Basin Management

**Article 10:**

The Ministry of Water Resources and Meteorology is responsible in leading, monitoring and coordinating and consulting with concerned institutions for the management, conservation, and development of all river basins in the Kingdom of Cambodia.

**Article 11**:

To manage, conserve and develop river basins in the Kingdom of Cambodia in an effective and sustainable manner two mechanisms shall be established as following:

1- The River Basin Management Committee at national level;
2- The Municipal/provincial River Basin Management Committee.

**Article 12:**

The composition of the River Basin Management Committee (RBMC) at national level is as following:

| | | |
|---|---|---|
| 1. | Minister of MOWRAM | Chairperson |
| 2. | Secretary of State of MoI (1pers) | Deputy Chair |
| 3. | Secretary of State of MPWT (1pers) | Deputy Chair |
| 4. | Secretary of State of MOWRAM (1pers) | Permanent Deputy Chair |
| 5. | Secretary of State of the Council of Ministers' Office(1pers) | Member |
| 6. | Secretary of State of MEF (1pers) | Member |
| 7. | Secretary of State of MOE (1pers) | Member |
| 8. | Secretary of State of MAFF (1pers) | Member |
| 9. | Secretary of State of MIH (1pers) | Member |
| 10. | Secretary of State of MME (1pers) | Member |

11. Secretary of State of MRD (1pers) Member
12. Secretary of State of MoT (1pers) Member
13. Secretary of State of MLUPC (1pers) Member
14. Secretary of State of MoP (1pers) Member
15. Secretary of State of Culture and Fine Arts(1pers) Member
16. Secretary of State of MoH (1pers) Member
17. Representative of the CNMC(1pers) Member

The exact composition of the RBMC at national level shall be defined by the decision of the Royal Government of Cambodia.

**Article 13:**

The RBMC at national level shall have the following roles and tasks:

- Prepare guidelines for sub-national level to prepare master plan, strategic development plan and action plan for the management, conservation and development of the river basin in accordance with national policy, national strategic development plan in the field of water resources and adopt those plans;
- Monitor, control and assess the implementation of the master plan, strategic development plan and action plan for the management, conservation and development of the river basin;
- Coordinate in the consultation with related stakeholders who rely on water resources in the river basin in the preparation of the master plan, strategic development plan and action plan for the management, conservation and development of the river basin;
- Timely inform local people on all activities related to water;
- Coordinate and settle all disputes relating to the management, conservation and development of the river basin;
- Custodian all documents and information related to issues and water resources activities in the river basin;
- Coordinate with ministries, institutions and development partners to conduct studies, research relating to the preparation of master plan, strategic development plan and action plan for the management, conservation and development of the river basin;
- Prepare annual report for the government; and
- Implement other tasks delegated by the government.

**Article 14**:

The RBMC at national level shall meet at least once per year following the invitation of the Chairperson. In case when the Chairperson is absent, the Chairperson shall delegate his/her full power to Deputy Chairperson to conduct the meeting.

In case of need, the Chairperson may invite representatives from other ministries, institutions, experts, technicians, or private sectors to participate in the consultative meeting or research on issues and activities related to the management of the river basin.

**Article 15**:

The RBMC at national level shall have a secretariat located in the MOWRAM for its smooth functionality.

The RBMC at national level have the rights to use the stamp of the MOWRAM.

The Secretariat of the RBMC at national level shall be led by a Chairperson of the Secretariat and accompanied by a number of Deputy Chairpersons as needed.

The organizing and functioning of the RMBC Secretariat shall be defined by the Prakas of the Minister of Water Resources and Meteorology.

**Article 16**:

The composition of a Municipal/Provincial River Basin Management Committee is as follows:

| | |
|---|---|
| - Governor of the Municipal/Provincial Governing Committee | President |
| - Vice-Governor of the Municipality/province | Vice-President |
| - Director of the PDWRM | Permanent Member |
| - Director of the Municipal/Provincial Department of Economy & Finance | Member |
| - Director of the Municipal/Provincial Department of Agriculture | Member |
| - Director of the Municipal/Provincial Department of Environment | Member |
| - Director of the Provincial Department of Public Works and Transport | Member |
| - Director of the Provincial Department of Industry and Handicrafts | Member |
| - Director of the Provincial Department of Mines and Energy | Member |
| - Director of the Provincial Department of Rural Development | Member |
| - Director of the Provincial Department of Tourism | Member |
| - Director of the Municipal/PDLMUPC | Member |
| - Director of Department of Planning | Member |
| - Director of the Forestry Compartment | Member |
| - Director of the from Fishery Compartment | Member |
| - Governor(s) of the concerned town(s), district(s), communes/sankats | Member |

In case of need, the president of the Committee may invite experts or representative from other Communities that are benefited from the basin to attend the meeting of the Committee as observers.

The exact composition of the Municipal/Provincial River Basin Management Committee shall be nominated by a decision of the President of the Municipal/Provincial RBM Committee.

**Article 17:**

The River Basin Management Committee at Municipal/Provincial level shall set up a secretariat for its effective functioning and shall have its own stamp. This secretariat shall locate in the provincial/municipal department of Water Resources and Meteorology, where the Governor of that municipal/provincial Governing Committee is the Chair of this RBM Committee. The Director of that municipal/provincial DWRAM shall be the Secretary of that RBMC.

The River Basin Management Committee at municipal/Provincial level shall convene its meeting at least twice a year. It may also call for extraordinary meetings if necessary.

The Chairperson of the River Basin Management Committee at Municipal/Provincial level shall make the report on its meeting outcomes and annual report on its working activities to the Chairperson of the River Basin Committee at national level.

**Article 18:**

A River Basin Management Committee at municipal/provincial level shall have the following tasks:

- Develop internal regulations, plans for the management, conservation, allocation, rehabilitation and development of river basins in line with the national policies in the field of water resources;
- Submit the plans to the RBMC at national level for review and approval;
- Monitor and coordinate the activities of ministries and institutions related to the implementation of plans for the management, conservation and development of the River Basin; Continue providing guidance on measures for water environment protection, water resources exploitation, use and development of water resources, and measures for the prevention and mitigation of risks caused by water in the river basin;
- Continue providing guidance on measures to specialized agencies in response to activities causing contamination to water environment;
- Timely communicate to local residents in the event of water-related catastrophes;
- Provide coordination and resolve conflicts within its competence;
- Implement other tasks as delegated by the RBMC at national level.

**Article 19:**

The duties of the Secretariat of the River Basin Management Committee at municipal/provincial level are as follows:

1- To provide support in administrative managements and financial arrangements to the River Basin Management Committee at municipal/provincial level in the development of plans for the management, conservation and development of the river basins;

2- To coordinate all activities concerning information collection, data management, and preparing reports for the River Basin Management Committee at municipal/provincial level;

3- To monitor and review the implementation of decisions taken by the River Basin Management Committee at municipal/provincial level; and

4- To undertake other tasks specifically delegated by the RBM Committee at municipal/provincial level to it.

**Article 20:**

The RBMC at national and at municipal/provincial levels shall have financial support for their smooth administrative functionality. These financial supports shall be within the package of the annual budget of MOWRAM and from other development partners.

## Chapter 5
## River Basin Management Planning

**Article 21:**

The RBMC at national level shall prepare master plan, strategic development plan and action plan for the management, conservation and development of the river basin for the management, conservation and development of the river basin in line with the National Strategic Development Plan and Public Investment Program of the Royal Government of Cambodia.

To prepare the master plan, strategic development plan and action plan for management, conservation and development of the river basin, the RBMC at national level shall ensure a wide consultation with ministries, institutions, RBMC at sub-national level, development partners and other concerned stakeholders and shall approve the master plan, strategic plan and action plan for their publication and dissemination to all stakeholders.

**Article 22:**

The development of the master plan, strategic plans and action plan for the management, conservation and development of the river basins should be considered based on the principles as states in Article 5 of this Sub-Decree.

**Article 23:**

The term of a master plan shall be between 10 and 15 years from the date of its approval by the RBMC at national level.

The term of the strategic plan shall be between 3 and 5 years from the date of its approval by the RBMC at national level.

The term of the action plan shall be between 1 and 3 years from the date of its approval by the RBMC at national level.

The RBMC shall lead, coordinate, monitor, follow up and assess the implementation of the river basin plan every semester in each year.

In case that the implementation of the any river basin plan was carried out positively, the RBMC at national level may extend the river basin plan, but not by more than 5 years from the end of the approved term of the plan. Any master plan, strategic plan and action plan for the management, conservation and development of the river basin, which was considered that it cannot be further implemented, the RBMC at national level shall instruct to amend the river basin plan accordingly.

The Procedures for the preparation of the master plan, strategic plan and development for the management, conservation and development of the river basin shall be defined in the Prakas of the Ministry of Water Resources and Meteorology.

## Chapter 6
## River Basin Management Measures

**Article 24:**

The main measures for river basin management are: the management of water quantity and quality; the protection of water sources; and the prevention and mitigation of risks caused by water.

The RBMC at national level shall develop a detail management manual, including guidelines and measures for of the river basin management.

**Article 25:**

The RBMC at national and at municipal/provincial levels shall implement, monitor and assess water resources, ground water and water related resources.

The activities for the monitoring and assessment of water and related resources in the river basin include:

- Survey and inventory of water resources, for quantity and quality of surface water and groundwater in each river basin;
- Survey on the water related environment in the river basin, including monitoring projected climate change impacts derived from regional climate models;
- Preparation for compiling of data and information products, including maps of river basin features, water related conservation areas, maps of aquifers, including recharge areas;
- Identifying and listing polluted, degraded and over-exploited water sources;
- Timely communicating on events related to water resources, on the survey of the current status of exploitation and use of water resources, and the current status of wastewater discharge to water sources;
- Develop and maintain an information and database system.

## Chapter 8
## Final Provision

**Article 26:**

Any regulation which is contrary with that of this Sub-Decree shall be considered null and void.

**Article 27:**

The Minister in charge of the Office of the Council of Ministers, Minister of Economy and Finance, Minister of Water Resources and Meteorology, ministers and state secretaries of ministries/institutions concerned shall implement this Sub-Decree as of this signing date onwards.

Phnom Penh, July 24, 2015

**Prime Minister**

**SamdechAkkaMohaSenaPadeiTecho HUN SEN**

**CC:**
- Ministry of Royal Palace
- General Secretariat of Constitutional Council
- General Secretariat of the Senate
- General Secretariat of the National Assembly
- General Secretariat of the Royal Government
- Cabinet of Samdech Prime Minister
- Cabinet of their Excellency/Lok Chumteav Deputy Prime Ministers
- Those as stated in Article 27
- The Royal Affairs
- Files-Archives

Annex I of the Sub-decree No. 98ank/bk, dated 24 July 2015 on the River Basin Management
Location Map of River Basins within the Kingdom of Cambodia



Annex II of the Sub-decree No. 98ank/bk, dated 24 July 2015, on the River Basin Management
List of River Basins and their size within the Kingdom of Cambodia

| Nr. | Code | Name of River Basin | Size ( $Km^2$ ) |
|---|---|---|---|
| I | River Basins within Coastal Region | | |
| 1 | 1 | Prek Kampong Bay | 3,018 |
| 2 | 2 | Prek Toek Sap | 1,529 |
| 3 | 3 | Prek Sre Ambel | 2,653 |
| 4 | 4 | Prek Andong Toek | 2,460 |
| 5 | 5 | Prek Trapang Rung | 2,615 |
| 6 | 6 | Prek Tatai | 1,619 |
| 7 | 7 | Prek Koh Pao | 3,109 |
| 8 | 8 | Stung Me Toek | 1,043 |
| | | Sub-Total I: | 18,045 |
| II | River Basins within Tonle Basac Region | | |
| 9 | 9 | Stung Toan-han | 1,765 |
| 10 | 10 | Stung Slakou | 2,485 |
| 11 | 11 | Stung Prek Thnot | 7,055 |
| | | Sub-Total II: | 11,305 |
| III | River Basins within Tonle Sap Region | | |
| 12 | 12 | Stung Krang Ponley | 3,033 |
| 13 | 13 | Stung Baribour | 3,003 |
| 14 | 14 | Stung Bamnak | 1,116 |
| 15 | 15 | Stung Pursat | 5,964 |
| 16 | 16 | Stung Svay Don Keo | 2,228 |
| 17 | 17 | Stung Moung Russei / Dauntry | 1,468 |
| 18 | 18 | Stung Sangker | 6,052 |
| 19 | 19 | Stung Mongkol Borey | 5,264 |
| 20 | 20 | Stung Sisophon | 5,593 |
| 21 | 21 | Stung Sreng | 9,931 |
| 22 | 22 | Stung Siem Reap | 3,619 |
| 23 | 23 | Stung Chikreng | 2,714 |
| 24 | 24 | Stung Staung | 4,357 |
| 25 | 25 | Stung Sen | 16,342 |

| Nr. | Code | Name of River Basin | Size ( $Km^2$ ) |
|---|---|---|---|
| 26 | 26 | Stung Chinit | 8,236 |
| 27 | 39 | Boeng Tonle Sap | 2,743 |
| | | Sub-Total III: | 81,663 |
| IV | River Basins within Northestern Region | | |
| 28 | 27 | Tonle Se Kong | 5,564 |
| 29 | 28 | Tonle Se San | 7,621 |
| 30 | 29 | Tonle Srepok | 12,780 |
| 31 | 30 | Prek Preah | 2,399 |
| 32 | 31 | Prek Krieng | 3,331 |
| 33 | 32 | Prek Kampi | 1,142 |
| 34 | 33 | Prek Te | 4,363 |
| 35 | 34 | Prek Chhlong | 5,599 |
| | | Sub-Total IV: | 42,800 |
| V | River Basins within Upper Mekong River Region | | |
| 36 | 35 | Mekong Riverine | 10,373 |
| | | Sub-Total V: | 10,373 |
| VI | River Basins within Southeastern Region | | |
| 37 | 36 | Tonle Vaico | 6,618 |
| | | Sub-Total VI: | 6,618 |
| VII | River Basins within Lower Mekong Delta Region | | |
| 38 | 37 | Mekong Delta Cambodia | 8,723 |
| 39 | 38 | Mekong Tonle Sap flood plains (Spean Troas) | 1,508 |
| | | Sub-Total VII: | 10,231 |
| | | TOTAL: | 181,035 |